**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០៣៩/២៤ ន.គ.ស

ថ្ងៃព្រហស្បតិ៍ ៦រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសបេក្ខជន បេក្ខនារីជាមន្ត្រីជាប់កិច្ចសន្យារបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឱ្យចូលបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ និស្សិត និងសាធារណជនទូទៅ ជ្រាបថា **ន.គ.ស.** ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារបស់ **អ.ស.ហ.** ឱ្យចូលបម្រើការងារនៅ **ន.គ.ស.** ចំនួន ៥ រូប ដែលនៅក្នុងនោះ ជំនាញគណនេយ្យនិងសវនកម្មចំនួន ៣ រូប ជំនាញនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈ ចំនួន ១រូប និងជំនាញព័ត៌មានវិទ្យាចំនួន ១រូប ស្របតាមលក្ខខណ្ឌនៃការជ្រើសរើសដូចខាងក្រោម÷

➢ **លក្ខខណ្ឌទូទៅ**

- ត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅទាក់ទងនឹងជំនាញគណនេយ្យនិងសវនកម្ម ជំនាញនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈ និងជំនាញព័ត៌មានវិទ្យា
- ត្រូវមានចំណេះដឹងភាសាអង់គ្លេសអាចប្រើប្រាស់ជាផ្លូវការបាន
- ត្រូវមានអាយុមិនលើស ៣៥ឆ្នាំ
- ត្រូវមានចំណេះដឹងកុំព្យូទ័រ (Microsoft Office and Email,....)
- ពុំធ្លាប់មានទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងជំនាញយ៉ាងតិច ០១ឆ្នាំ ទៅតាមផ្នែក និងជំនាញខាងលើ
- ត្រូវមានការព្យាយាម និងតស៊ូបំពេញការងារ និងមានអត្តចរិកស្លូតត្រង់ និងម៉ឺងម៉ាត់

ការជ្រើសរើសនេះនឹងត្រូវធ្វើឡើងតាមរយៈការសម្ភាសន៍ផ្ទាល់មាត់។ បេក្ខជន ឬបេក្ខនារីដែលមានចំណាប់-អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) និង Cover Letter ព្រមទាំងឯកសារពាក់ព័ន្ធមកកាន់ (**ន.គ.ស.**) ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី...៥.....ខែ..កក្កដា..ឆ្នាំ២០២៤ វេលាម៉ោង ១៦ :០០ នាទីល្ងាច។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈលេខទូរស័ព្ទ ០២៣ ៨៨២១១១, ០៧០ ២៩ ២៩ ៧១។

អាសយដ្ឋាននិយ័តករគណនេយ្យនិងសវនកម្ម÷ អគារ "ក" ជាន់ទី ១ នៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**និយ័តករគណនេយ្យនិងសវនកម្ម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០៨៥ - ២៣ ៨៨២ ១១១
Phone: 023 882 111